ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះតុលាការកំពូល
Supreme Court Chamber
Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក (១៨)

Case File/Dossier Nº. 002/19-09-2007-ECCC-TC/SC (18)

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 08-May-2013, 15:48
CMS/CFO: Sann Rada

នៅចំពោះមុខ៖

ចៅក្រម គង់ ស្រីម ប្រធាន
ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម Agniezska KLONOWIECKAMILART
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម Judge Florence Ndepele Mwachande MUMBA
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម យ៉ា ណារិន

| | |
|---|---|
| កាលបរិច្ឆេទឯកសារ៖ | ថ្ងៃទី ០៨ /ខែ ឧសភា /ឆ្នាំ ២០១៣ |
| ភាសាដើម៖ | ខ្មែរ/អង់គ្លេស |
| ចំណាត់ថ្នាក់ឯកសារ៖ | សាធារណៈ |

---

# សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំការបង្គាប់ជាបន្ទាន់ទៅអង្គជំនុំជម្រះ សាលាដំបូងឲ្យចេញសេចក្តីសម្រេច ដែលមានសំអាងហេតុស្តីពីការបំបែក កិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២

---

**សហព្រះរាជអាជ្ញា**

ជា លាង

Andrew CAYLEY

**សហមេធាវីជនជាប់ចោទ នួន ជា**

សុន អរុណ

Victor KOPPE

**សហមេធាវីជនជាប់ចោទ ខៀវ សំផន**

00908165



**<u>ជនជាប់ចោទ</u>**

ខៀវ សំផន

នួន ជា

គង់ សំអុន

Anta GUISSÉ
Arthur VERCKEN
Jacques VERGÈS

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ

Elisabeth SIMONNEAU FORT

1. **អង្គជំនុំជម្រះតុលាការកំពូល** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យក្នុងអំឡុងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩ ("អង្គជំនុំជម្រះតុលាការកំពូល" និង "អ.វ.ត.ក") បានទទួល"សំណើរបស់សហព្រះរាជអាជ្ញា សុំការបង្គាប់ជាបន្ទាន់ទៅអង្គជំនុំជម្រះសាលាដំបូងឱ្យចេញសេចក្ដីសម្រេចដែលមានសំអាងហេតុស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២" ដែលបានដាក់នៅថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៣ ("សំណើ")[1]។

2. នៅថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូល បានចេញ"សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីវិសាលភាពនៃសំណុំរឿង ០០២/០១"[2] ("សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខ") ដោយប្រកាសថា អានុភាពត្រួតគ្នានៃកំហុសមួយចំនួនរបស់អង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធនឹងការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ បានបណ្ដាលឱ្យការបំបែកកិច្ចដំណើរការនីតិវិធីនេះគ្មានសុពលភាព[3]។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខ មិនមានផលប៉ះពាល់ដល់ការវាយតម្លៃឡើងវិញរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកសំណុំរឿង ០០២ ឡើយ ប៉ុន្តែថា "អង្គជំនុំជម្រះត្រូវអញ្ជើញភាគីនានាឱ្យដាក់សារណាលើលក្ខខណ្ឌនៃដីកានេះ ហើយនៅពេលដែលអត្ថប្រយោជន៍របស់ភាគី *ទាំងអស់*ត្រូវបានធ្វើឱ្យមានតុល្យភាពចំពោះកត្តាពាក់ព័ន្ធផ្សេងៗហើយនោះ ការបំបែកកិច្ចដំណើរការនីតិវិធីលើសំណុំរឿង ០០២ អាចធ្វើទៅបានប្រកបដោយភាពសមស្រប"[4]។

3. បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈភ្លាមៗមួយ ដោយកំណត់កាលបរិច្ឆេទសវនាការនៅថ្ងៃទី ១៤ និងថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៣ ហើយបានលើកបញ្ហាជាក់លាក់ និងលម្អិតចំនួន ៩ ចំណុចទាក់ទិននឹងការបំបែកកិច្ចដំណើរការនីតិវិធីសំណុំរឿង០០២ ដើម្បីឱ្យភាគីទាំងអស់ដោះស្រាយ[5]។

---

[1] ឯកសារ E163/5/1/13/2។

[2] ឯកសារ E163/5/1/13។

[3] សេចក្ដីសម្រេច កថាខណ្ឌ ៤៩។

[4] សេចក្ដីសម្រេច កថាខណ្ឌ ៥០ (សេចក្ដីបញ្ជាក់ដើម)។

[5] អនុស្សរណៈ ពីចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "ការណែនាំដល់ភាគីនានាដោយសារតែមានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹង

ក្រោយមកទៀត សវនាការត្រូវបានកំណត់កាលបរិច្ឆេទឡើងវិញទៅថ្ងៃទី ១៨ និងថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣[6]។ នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសនៅក្នុងតុលាការថា អង្គជំនុំជម្រះបានសម្រេចបំបែកសំណុំរឿង ០០២ ឡើងវិញ ឲ្យទៅជាការជំនុំជម្រះតូចៗដាច់ចេញពីគ្នា ហើយថា វិសាលភាពនៃការជំនុំជម្រះនៅដំណាក់កាលដំបូង ("សំណុំរឿង ០០២/០១") នឹងត្រូវបានកម្រិតត្រឹមតែបទចោទនានាទាក់ទិននឹងការជម្លៀសប្រជាជនក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២ និងទីតាំងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ ("សេចក្ដីសម្រេចផ្ទាល់មាត់")[7]។ អង្គជំនុំជម្រះសាលាដំបូងក៏បានចង្អុលបង្ហាញថា សំអាងហេតុសម្រាប់សេចក្ដីសម្រេចផ្ទាល់មាត់នេះនឹងចេញជាលាយលក្ខណ៍អក្សរនៅពេលឆាប់ៗខាងមុខនេះ[8]។

4. បន្ទាប់ពីរង់ចាំសំអាងហេតុជាលាយលក្ខណ៍អក្សរអស់រយៈពេល ២៥ ថ្ងៃ រួចមក សហព្រះរាជអាជ្ញាបានដាក់សំណើសុំដោយអនុលោមតាមវិធាន ១០៤, ១០៥, ១០៦(២) និង ១០៧ នៃវិធានផ្ទៃក្នុង[9] ដោយលើកទឡ្ហីករណ៍ថា ការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការផ្ដល់សំអាងហេតុណាមួយ មកដល់ពេលនេះ គឺមិនសមហេតុផលទេ និងជាការរំលោភឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនាំឲ្យប៉ះពាល់យ៉ាងខ្លាំងចំពោះភាគីទាំងអស់[10]។ ចំពោះបញ្ហានេះ សហព្រះរាជអាជ្ញាលើកឡើងថា សិទ្ធិប្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា"បច្ចុប្បន្ននេះនឹងក្លាយជាគ្មានន័យ ឬត្រូវធ្វើឡើងដោយឆាប់រហ័សពេក ដោយហេតុថា៖ (i) ពេលវេលាកាន់តែខ្លីដែលបណ្ដាលមកពីសវនាការនេះត្រូវបានបំបែកនោះ គឺនឹងត្រូវបញ្ចប់។ (ii) កាលបរិច្ឆេទសម្រាប់រយៈពេលបីខែ ដែលមានចែងក្នុងវិធាន ១០៨ (៤)*ស្ទួន* នៃវិធានផ្ទៃក្នុងសម្រាប់ចេញសេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗ និង (iii) ជាលទ្ធផល ការរំពឹងទុកចំពោះការអនុវត្តឲ្យមានប្រសិទ្ធភាពចំពោះដំណោះស្រាយណាមួយ ដែលអាចផ្ដល់ជូនទៅលើ បណ្ដឹងសាទុក្ខភ្លាមៗ

---

សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីវិសាលភាពនៃសំណុំរឿង ០០២/០១ (ឯកសារ E163/5/1/13)" ឯកសារ E163/5/1/13/1 ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៣ និងដាក់នៅថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[6] ប្រតិចារឹក ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E1/171.1 ទំព័រ 6, 114។

[7] ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ E1/176.1 ទំព័រ 4។

[8] ប្រតិចារឹក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ E1/176.1 ទំព័រ 2-4។

[9] វិធានផ្ទៃក្នុងនៃ អ.វ.ត.ក វិសោធនកម្មលើកទី៨ ចុះថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១១ ("វិធានផ្ទៃក្នុង")

[10] សំណើ កថាខណ្ឌ ១, ៣, ១៨-៣១។ សហព្រះរាជអាជ្ញាក៏អះអាងផងដែរថា សំណើនេះអាចទទួលយកបាន។ សូមមើល សំណើ កថាខណ្ឌ ២, ១១-១៨។

នេះ”[11]។ ដូច្នេះ សហព្រះរាជអាជ្ញាស្នើឲ្យអង្គជំនុំជម្រះតុលាការកំពូល “ដោះស្រាយដោយផ្ទាល់ចំពោះផលប៉ះពាល់ដល់សិទ្ធិដែលបានកើតឡើង”[12] ដោយបង្គាប់ឲ្យអង្គជំនុំជម្រះសាលាដំបូងផ្តល់សំអាងហេតុជាលាយលក្ខណ៍អក្សរសម្រាប់សេចក្តីសម្រេចផ្ទាល់មាត់ ដោយមិនពន្យារពេលទៀតឡើយ[13]។

5. បីថ្ងៃបន្ទាប់ពីសហព្រះរាជអាជ្ញាបានដាក់សំណើរបស់ខ្លួនរួចមក អង្គជំនុំជម្រះសាលាដំបូងបានចេញសំអាងហេតុជាលាយលក្ខណ៍អក្សររបស់ខ្លួនសម្រាប់សេចក្តីសម្រេចផ្ទាល់មាត់[14]។ ដូច្នេះ សំណើនេះត្រូវបានចាត់ទុកជាអសារបង់ និងត្រូវបដិសេធចោលដោយពុំចាំបាច់ធ្វើការពិចារណាលើអង្គសេចក្តី ឬភាពអាចទទួលយកបាននោះឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ជាការចាំបាច់ក្នុងការបញ្ជាក់ថា អង្គជំនុំជម្រះតុលាការកំពូលពុំយល់ឃើញថា នៅពេលដាក់សំណើនេះ សិទ្ធិប្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ត្រូវបានក្លាយជាគ្មានន័យ ឬស្ទើរតែគ្មានន័យ ដោយសារតែ ការពន្យារពេលរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការចេញសំអាងហេតុជាលាយលក្ខណ៍អក្សររបស់ខ្លួននោះឡើយ។ ទោះបីជាភ័ស្តុតាងក្នុងសំណុំរឿង ០០២/០១ ត្រូវបញ្ចប់ នៅមុនពេលផុតកំណត់កាលបរិច្ឆេទសម្រាប់ចេញសេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗជាយថាហេតុនោះក៏ដោយ ក៏ការប៉ះពាល់ដល់សិទ្ធិណាមួយ ដែលអាចកើតចេញពីកំហុសណាមួយនោះ តម្រូវឱ្យមានការធ្វើអន្តរាគមន៍ និងការពិនិត្យពិច័យលើបណ្តឹងសាទុក្ខ តាមការចាំបាច់ ឬទៅតាមកាលៈទេសៈសមស្រប។

---

[11] សំណើ កថាខណ្ឌ ៣។ សូមមើល ផងដែរ សំណើ កថាខណ្ឌ ២៣-៣០។

[12] សំណើ កថាខណ្ឌ ៣១។

[13] សំណើ កថាខណ្ឌ ១, ៣២។

[14] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E284 ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣។

6. **យោងតាមសំអាងហេតុខាងលើនេះ អង្គជំនុំជម្រះតុលាការកំពូល:**

**សម្រេចបដិសេធ** លើសំណើនេះ។

ភ្នំពេញ ថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០១៣

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ីម**